# សាំង អូហ្គូស្ទីន

76

354-430

Moral Civic Education - NIE

## *Saint Augustin*



# ប្រវត្តិសង្ខេប

# ប្រវត្តិ និងបុគ្គលិកលក្ខណៈ

- កើតនៅ នុយមីឌី (Numidia) នៃតាហ្កាត (Thagaste) នាឆ្នាំ ៣៥៤ លោកជា កូនរបស់ស្ត្រីដែលកាន់សាសនាគ្រីស្តម្នាក់មេម៉ាយក្នុងអាយុ២០ឆ្នាំ ចិញ្ចឹមកូនតែមួយ តាំងពីពេលនោះមក ។
- ក្រោយសិក្សាអក្សរសាស្ត្រលោក អូហ្គូស្តាំង ប្រកបមុខរបរជាសាស្ត្រាចារ្យអក្សរសាស្ត្រ ។ លោក បានចូលសាសនាគ្រីស្តនៅឆ្នាំ៣៨៧ ហើយក្លាយជាជាអាចារ្យនៃសាសនានេះនៅឆ្នាំ៣៩២ ហើយបាន ក្លាយជាមេសាសនាគ្រីស្តនៅក្រុង Hippone នាឆ្នាំ៣៩៦ ។
- នៅឆ្នាំ៤២៩ ទ្វីបអាហ្វ្រិកបានធ្លាក់ក្នុងការ ទន្ទ្រាននៃពួកចោរព្រៃ គឺពួក Vandales ដែលកាន់កាប់ទីក្រុង Hippone ហើយ អូហ្គូស្ទាំង បានស្លាប់ក្នុងពេលកាន់កាប់ទីក្រុងនេះដោយពួកចោរព្រៃនោះទៅ ។

# ប្រវត្តិ និងបុគ្គលិកលក្ខណៈ

- អូហ្គូស្តាំង គឺជាមេដឹកនាំព្រះវិហារសាសនាគ្រិស្តដ៏ល្បីល្បាញម្នាក់នាសម័យកាលដែលគ្រិស្តសាសនាជាសាសនានាំមុខនៅក្រុងរ៉ូមនាសតវត្សទី ៤-៥ គ.ស ។ លោក គឺជាទស្សនវិទូគ្រិស្តសាសនា ជាអ្នកទេវវិជ្ជា និងជាអ្នកតំណាងឲ្យពួកមហាថេរៈឡាតាំង ។
- អូហ្គូស្តាំង គឺជាអ្នកចេះចាំស្ទាត់នូវទស្សនវិជ្ជាក្រិច និងរ៉ូម៉ាំង ។ លោក គឺជាបុគ្គលដែលមានជំហរនៅចន្លោះបុរាណសម័យ និងមជ្ឈិមសម័យ ។ លោកបានទទួលឥទ្ធិពលពីទស្សនវិជ្ជារបស់ ប្លាតុង និងស៊ីសេរ៉ុង ។
- តាមរយៈស្នាដៃដែលល្បីល្បាញជាងគេ "បុរីអាទិទេព" (The city of God) បង្ហាញថាលោកមានទស្សនៈឈរលើមូលដ្ឋាននៃអធិធម្មជាតិនៃគ្រិស្តសាសនា (Mystic Christianism) និងទេវវិជ្ជា (Mythology) ដែលបង្ហាញថា ប្រវត្តិសាស្ត្ររបស់មនុស្សលោកស្ថិតក្រោមឥទ្ធិពលទិព្វញាណរបស់អាទិទេពស្តីអំពីបាបរបស់អាដាម (Adam) និងនាងអេវ (Eve) ។
- លោកបង្ហាញថា ការដោះស្រាយបញ្ហាមនុស្សដោយគ្មានទំនាក់ទំនងជាមួយអាទិទេព ជាគំរូនៃអំពើដែលប្រឆាំងនឹងអាទិទេពដែលត្រូវតែជៀសវាងជាដាច់ខាត ។
- បានសេចក្តីថា រាល់ការសម្រេចចិត្តរបស់មនុស្ស ដោយខ្លួនឯងខុសពីឆន្ទៈរបស់អាទិទេពសុទ្ធសឹងជាកំហុស ។

# ទស្សនៈនយោបាយ

# ក.បុរីមនុស្ស អានិទេព អំណាច

❖ រដ្ឋ ស្ថាប័នគ្រង់គ្រងរដ្ឋ ប្រព័ន្ធច្បាប់ ដែលមនុស្សបង្កើតឡើងសុទ្ធសឹងតែជាលទ្ធផលនៃអំពើបាប ។ មនុស្សគ្មានសមត្ថភាពបង្កើត ដកខ្លួនឲ្យចេញពីអំពើបាបឡើយ ហេតុនេះ មនុស្សក៏ពុំមានសមត្ថភាពបង្កើតសង្គមសុក្រិតដោយខ្លួនឯងផ្ទាល់បានដែរ ។



**រដ្ឋ គឺជាដំណើរនៃការឯកភាពសង្គមមួយ ដែលផ្ដើមចេញពីការបង្រួបបង្រួមគ្រួសារ ។ គ្រួសារគឺជាការបង្រួបបង្រួមមនុស្ស ដូច្នេះរដ្ឋ គឺជាលទ្ធផលនៃការបង្រួបបង្រួមមនុស្សតាមការរុញច្រានរបស់ធម្មជាតិ ។**

❖ បុរីសម្រាប់មនុស្ស ជាកន្លែងដែលអំពើអាក្រក់តែងកើតមានឡើង និងបុរីរបស់អាទិទេព ជាកន្លែងតែមួយដែលមានតែអំពើល្អ ។ អាទិទេពតំណាងនៅលើផែនដីដោយព្រះវិហារ ។

❖ អាជ្ញាគឺចេញមកពីសិទ្ធិរបស់អាទិទេព គឺអាទិទេពជាអ្នកប្រគល់នូវអាជ្ញា ហើយគ្មានអ្នកណាមួយអាចចាត់ទុកអំណាចថាជាកម្មសិទ្ធិរបស់ខ្លួនឡើយ ។




# បេសកម្មនៃអំណាច
# គឺ
# ធ្វើឲ្យមានយុត្តិធម៌

ហេតុដូចនេះហើយបានជាអំណាច
ត្រូវបានប្រគល់ឲ្យស្តេច ឬអធិរាជ
ដែលជាមេ ។

# អ្នកកាន់អំណាចត្រូវមានភាតព្វកិច្ចបីយ៉ាង

## ១. សេវាកម្មបញ្ជា

- មេបញ្ជាតាមឆន្ទៈរបស់ខ្លួន តែក៏មិនគិតថាខ្លួននោះខ្ពង់ខ្ពស់ជាងគេទេ ព្រោះមិន ត្រូវភ្លេចថាខ្លួនជាមនុស្សម្នាក់ដូចគេឯទៀតដែរ ។

## ២. ជាកន្លែងគិតទុកមុន

- មេជាអ្នកកំណត់ផលប្រយោជន៏នៃរដ្ឋ ហើយជាអ្នកផ្តល់នូវក្តីពេញចិត្ត ។
- ការត្រៀមផែនការ និងលក្ខណៈជាមុន ជាមុខងាររបស់មេ ប្រើប្រាស់អំណាចគឺដើម្បីផាសុកភាពនៃប្រជាជនដោយគ្មានកៀបសង្កត់ និងភាពបោកប្រាស់ ។

## ៣. ជាទីប្រឹក្សានៃប្រជាជន



- បញ្ជា គឺបម្រើ ។ បើព្រះមហាក្សត្របញ្ចេញនូវឆន្ទៈរបស់ព្រះអង្គ អាជ្ញាត្រូវតែយល់ព្រម យកទៅបម្រើដោយក្តីស្រឡាញ់ដូចអំពើល្អមួយ ។
- អូហ្គូស្តាំង បានទុកឲ្យយើងនូវកម្មវិធី នយោបាយបីប្រភេទគឺ បញ្ជា បង្រួមគ្នា សន្តិភាព ។
- បញ្ជាទទួលបានឲ្យការបង្រួមគ្នាឯកភាព ហើយឯកភាពសម្រេចបានជាសមិទ្ធិផលដោយសន្តិភាព

# រដ្ឋាភិបាល




រដ្ឋាភិបាលទាំងអស់គឺល្អ

ក្នុងលក្ខខ័ណ្ឌ ក្នុងវិស័យសីលធម៌

និងសាសនា ជាអ្នកគោរព

អាទិទេព និងគោរពមនុស្ស ។

# ២. អាណាចក្រ និងព្រះវិហារ

- Augustin បែងចែកអំណាចដាច់ពីគ្នាច្បាស់លាស់នូវអំណាចស៊ីវិល និង អំណាចព្រះវិហារ ម្នាក់ៗ ធ្វើការបម្រើវិស័យរបស់ខ្លួនដោយមានឯករាជ្យភាពរៀងៗខ្លួន ។
- ព្រះវិហារទោះបីស្ថិតនៅពីលើរដ្ឋ ដោយខ្លួនជាអ្នកចម្លងអ្វីៗទៅព្រះអាទិទេព តែទទួលស្គាល់ច្បាប់សំខាន់នៃពិភពផែនដីហើយព្រមគោរព តាមច្បាប់នោះផង ។
- មនុស្សជាតិមានតែមួយទេ ហើយរដ្ឋតូចៗងាយស្រួលគ្រប់គ្រង ។ លោកចង់បាននូវរដ្ឋតូចៗងាយគ្រប់ គ្រងក្នុងពិភពលោកនេះ ក៏ដូចជាមានគ្រួសារជាច្រើននៅក្នុងបុរី ។

# ២. អាណាចក្រ និងព្រះវិហារ

- អូហ្គូស្តាំង បានយកគំនិតរបស់លោក ប៉ូល ដែលនិយាយថា "អំណាចទាំងអស់កើតចេញពីអាទិទេព" ប៉ុន្តែ អូហ្គូស្តាំង ពន្យល់ថា អាជ្ញាធរគឺមិនអាចចោលបាន
- ការចង្អុលបញ្ហាញពីអ្នកកាន់តំណែងនៃអំណាចនេះ និងស្ទីលនៃរបបដឹកនាំកើតលទ្ធផលចេញពីអំពើរបស់មនុស្ស នេះគឺជាការប្រព្រឹត្តទៅដោយខ្លួនឯងរបស់មនុស្ស ។
- មនុស្សជាអ្នកដែលត្រូវធ្វើការសម្រេចចិត្តជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន ។ ផ្ទុយទៅវិញ អូហ្គូស្តាំង ទាមទារពីភាពចាំបាច់ដាច់ខាតនៃការគោរពតាមព្រោះហេតុថា ប្រភពដើមនៃអំណាចគឺជាអាទិទេព ។

# ២. អាណាចក្រ និងព្រះវិហារ

❖ ប្រវត្តិសាស្ត្រដែលជាបន្ទាត់មួយអំពីការវិវត្តមិនឈប់ឈរតាំងពីបាបកម្មដំបូងរហូតដល់ការលាងបាបចុងក្រោយ ។ ហេតុនេះបណ្ដាសញ្ញាណទាំងនោះ គឺស្ថិតនៅក្នុងកណ្ដាប់ដៃនៃវាសនារបស់ពួកគេ ។



Moral Civic Education - NIE

**“ បើគ្មានយុត្តិធម៌ទេ ព្រះរាជាណាចក្រ អាណាចក្រ ឬរដ្ឋ គឺជាសមាគមចោរដ៏ធំបំផុត ”**

# ២. អាណាចក្រ និងព្រះវិហារ

- អំណាចនយោបាយកើតចេញពីឆន្ទៈរបស់អាទិទេព ។ អាទិទេពកំណត់រួចជាស្រេចថា អ្នកណាជាអ្នកដឹកនាំ ។ ពុំមែនកើតឡើងពីការបន្តវង្សត្រកូល ឬតាមរយៈសន្លឹកឆ្នោតនោះឡើយ ។
- ចំពោះទម្រង់អំណាច និងអ្នកកាន់អំណាចវិញ គឺជាបញ្ហារបស់មនុស្ស មនុស្ស គឺជាអ្នកកំណត់ថា តើត្រូវប្រើប្រាស់អំណាចនោះក្នុងរូបភាពបែបណា?
- ការផ្តល់យុត្តិធម៌ និងសន្តិភាព ការឯកភាពរវាងអ្នកដឹកនាំ និងអ្នកត្រូវគេដឹកនាំ ជាគោលបំណងសំខាន់របស់អំណាច
- រដ្ឋដែលមិនបានគិតគូរពីបញ្ហាយុត្តិធម៌សង្គម គឺរដ្ឋដែលមានលក្ខណៈឆក់ប្លន់ ។

# ២. អាណាចក្រ និងព្រះវិហារ

ចំពោះទម្រង់រដ្ឋវិញ ទោះទម្រង់ជាបែបណា ក៏ដោយក៏មិនសំខាន់ដែរ សំខាន់អោយតែ ទម្រង់ណាមួយ (ទម្រង់រដ្ឋធ្លាប់មានស្រាប់ ហើយក្តី) នោះអាចគោរពអាទិទេព និងមនុស្សតាមលំដាប់នៃយុត្តិធម៌ និង ជំនឿដាក់លើគម្ពីសាសនា ។

# ១. អាណាចក្រ និងព្រះវិហារ

- អំពីកម្មសិទ្ធិវិញ គឺអ្នកកាន់សាសនាត្រូវតែមានកម្មសិទ្ធិរួមគ្នា ។ តាមធម្មជាតិ មនុស្សមានកម្មសិទ្ធិរួមគ្នា ប៉ុន្តែមនុស្សម្នាក់ៗ អាចទាញយកផលប្រយោជន៍សម្រាប់បំរើតម្រូវការរបស់ខ្លួនបាន ចេញពីផលប្រយោជន៍រួមនោះ ។
- កម្មសិទ្ធិពុំមែនកំណត់ដោយមនុស្សឡើយ គឺអាទិទេពជាអ្នកកំណត់ ហើយអ្នកមានកម្មសិទ្ធិតែងតែជាមនុស្សដែលប្រកបដោយគុណធម៌ និយាយរួមទាល់តែជាអ្នកបួសទើបមានលក្ខណៈសម្បត្តិនេះបាន ។
- កម្មសិទ្ធិខ្លះទៀត កើតចេញពីការកំណត់របស់មនុស្ស តាមរយៈច្បាប់ដែលគេតាក់តែងឡើង ដូច្នេះគេក៏អាចលុបច្បាប់នោះចោលវិញបានដែរ ។

- អំណាចសាសនា និងអំណាចរដ្ឋមានអធិបតេយ្យភាពរៀងៗខ្លួន តែត្រូវមានអន្តរកម្មជាមួយគ្នា ដោយរដ្ឋត្រូវការពារសាសនាពីសត្រូវនានា តាមកម្លាំងអាវុធ រីឯព្រះវិហារវិញ ត្រូវជួយអំណាចរដ្ឋដោយអប់រំស្មារតីពលរដ្ឋទាំងអស់ តាមរយៈគម្ពីសាសនា ។